រតនត្តយប្បណាម

(ធម៌នមស្ការព្រះរតនត្រ័យ)

ប្រមូលចងក្រងដោយ

ហ្វួយ វ៉ាន់ថន

ព.ស. ២៥៦៣

រតនត្តយប្បណាម

(ធម៌នមស្ការព្រះរតនត្រ័យ)

ប្រមូលចងក្រងដោយ

ហួយ វ៉ាន់ថន

ព.ស. ២៥៦៣

ឈ្មោះសៀវភៅ	**រតនត្តយប្បណាម**
	(ធម៌នមស្ការព្រះរតនត្រ័យ)
រៀបរៀងដោយ	*ហួយ វ៉ាន់ថន*
ទីតាំងធ្វើ	*ពុទ្ធិកបណ្ឌិតសភា*
ការផ្សាយ	*របស់ពុទ្ធិកបណ្ឌិតសភា*
រក្សាសិទ្ធិ	*ពុទ្ធិកបណ្ឌិតសភា*
កាលបរិច្ឆេទ	*ថ្ងៃពុធ ៤ កើត ខែផគ្គុន ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣, ចុល្លសករាជ ១៣៨១, មហាសករាជ ១៩៤១*
	ត្រូវនឹងថ្ងៃទី ២៦ ខែ កុម្ភៈ គ.ស. ២០២០

រតនត្តយប្បណាម

មាតិកា ទំព័រ

មាតិកា	ទំព័រ
ទេវតាយាចនគាថា	៣
ធម៌ថ្វាយបង្គំព្រះប្រាំព្រះអង្គ	៣
បទលើកទង់ព្រះពុទ្ធសាសនា	៥
បទដាក់ទង់ព្រះពុទ្ធសាសនា	៥
បទសរភញ្ញ (បទបថ្យាវត្ត)	៧
រតនត្តយបូជា	៨
ពុទ្ធរតនប្បណាម	៨
ធម្មរតនប្បណាម	១៣
សង្ឃរតនប្បណាម	១៧
រតនប្បណាមគាថា	២៣
នមស្ការបូជនីយវត្ថុ	២៥
នមស្ការពុទ្ធបាទ	២៦
វិធីសមាទានសីល ៥	២៨
វិធីសមាទានសីល ៨	៣៣
ពុទ្ធជយមង្គល	៣៩

បារមី ៣០	៤៦
អនុស្សតិ ១០	៥៣
បត្តិទានគាថា	៥៥
យំ កិញ្ចិ ប្រែកាព្យ	៥៥
យំ កិញ្ចិ ប្រែកាព្យមួយបែបទៀត	៥៧
តេជះខ្ញុំសាង(កាព្យ)	៥៨
វិសាខាឧទាន	៥៩
តាំងសេចក្តីប្រាថ្នា	៦១
ទានចិញ្ចឹមបុត្រ	៦២
អន្ទង់ទាំងបួន	៦៣
ធម៌ផ្សាយមេត្តា	៦៥
អនុមោទនារក្ខាយាចនគាថា	៦៧
ថ្វាយបង្គំរតនត្រៃ	៦៩
សិទ្ធិយាចនគាថា	៧០
ភាសិតធម៌	៧០
អធិដ្ឋានចិត្ត	៧១

រតនត្តយប្បណាម

ទេវតាយាចនគាថា

សមន្តា ចក្កវាឡេសុ   អត្រាគច្ឆន្តុ ទេវតា
សទ្ធម្មំ មុនិរាជស្ស   សុណន្តុ សគ្គមោក្ខទំ ។

ទេវតាទាំងឡាយ ក្នុងចក្រវាឡទាំងឡាយ ដោយជុំវិញ សូមអញ្ជើញមកប្រជុំគ្នាក្នុងទីនេះ ចូរស្តាប់នូវព្រះសទ្ធម្ម ជាធម៌អាចឲ្យនូវសួគ៌ និងព្រះនិព្វាន (របស់ព្រះអនាវរណញ្ញាណ) ជាស្តេចនៃអ្នកប្រាជ្ញ ។

ធម៌ថ្វាយបង្គំព្រះប្រាំព្រះអង្គ

ឱកាសខ្ញុំសូមវន្ទា   នូវព្រះឈ្នះមារ   ទាំងប្រាំព្រះអង្គ
សូមយាងព្រះបារមី   ម្ចាស់ថ្ងៃមកគង់   នៅនាកំឡុង
ទីស្ថាននេះណា ។

ព្រះកកុសន្ធោ   ព្រះកោណាគមនោ   ព្រះកស្សបោ

ព្រះសមណគោតម   បរមពុទ្ធោ   ព្រះមេត្តេយ្យោ
ព្រះពោធិសត្វថ្ងៃ ។

ព្រមទាំងព្រះធម៌ ជ្រាលជ្រៅបវរ ប្រសើរពេកក្រៃ

ប្រាំបីម៉ឺនបួនពាន់ ព្រះធម្មក្ខន្ធនេះនៃ របស់ព្រះជិនស្រី

ទីទៃរាល់អង្គ ។

ព្រមទាំងព្រះសង្ឃ ប្រសើរសីលទ្រង់ ជាបុត្តព្រះពុទ្ធ

លះកាត់តណ្ហា ប្រសើរបំផុត ខ្ញុំសូមលំអុត

កាយវាចាចិត្ត ។

ដោយតេជះខ្ញុំ លើកហត្ថបង្គំ ត្រៃរតនា

សូមកម្ចាត់បង់ សត្រូវនានា ទុក្ខសោករោគា

វិនាសទៅហោង ៕

បទលើកតម្កល់ព្រះពុទ្ធសាសនា

១. សូមមើលទង់ជ័យ ឆព្វណ្ណរង្សី ដែលមានរស្មីភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណ៌ស ហង្សបាទនិងពណ៌ដ៏ភ្លឺផ្ទេក ។
២.ប្រទេសតូចធំ បានស្ម័គ្រស្មាគមន៍ ជំនុំគ្នាច្រើនអនេក
ព្រមយករស្មី ព្រះពុទ្ធគួរត្រេក ប្រសើរពន់ពេកក្រៃកន្ទង ។
៣.ធ្វើជាសញ្ញា ទង់ជ័យសាសនា នៃព្រះសម្ពុទ្ធធំចម្បង
ចូរយើងរាល់គ្នា យកចិត្តចាំចង នឹកដល់ព្រះអង្គជាអម្ចាស់ ។
៤.ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា សុទ្ធសឹងតែជាពុទ្ធសាសន៍
ចូរយើងសាមគ្គី ទាំងក្មេងទាំងចាស់ ប្រឹងប្រែងឱ្យណាស់គ្រប់ៗគ្នា ។
៥.សូមសាសនាពុទ្ធ ថ្កុំថ្កើងបំផុត រុងរឿងវិសុទ្ធថ្លៃថ្លា
ហើយមានជ័យជោគ ផ្សាយពេញលោកា ដោយជនជ្រះថ្លាច្រើនសែនលាន។
៦.មានចិត្តស្នេហា គោរពបូជា ចំពោះព្រះធម៌ដ៏កល្យាណ
ទាំងមនុស្សទេវតា ស្នេហាគ្រប់ប្រាណ ប្រាថ្នាចង់បានសេចក្តីសុខ ។
៧.យើងខេមរជាតិ នាំគ្នាខ្មីឃ្មាត កាន់ធម៌នឹងបានផុតទុក្ខ
រួបរួមសាមគ្គី ពីនេះទៅមុខ យើងនឹងបានសុខក្សេមក្សាន្តត្រាណ។
៨.ព្រមព្រៀងប្រព្រឹត្ត កាន់ធម៌សុចរិត ឆ្ពោះទៅកាន់ស្ថាននិព្វាន
ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត ជាតិយើងនឹងបានសោយសុខា។

បទដាក់តម្កល់ព្រះពុទ្ធសាសនា

-ជាតិយើងអ្នកកាន់សាសនា ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី គឺព្រះរស្មីទាំងប្រាំមួយពណ៌ ។

-ផ្សាយចេញពីព្រះកាយទ្រង់ រុងរឿងឫទ្ធិរុងប្រសើរបវរ
ធ្លៀលធ្វាត់កាយធើតធាយល្អ ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា ។
-កំណើតនៃព្រះរស្មី កើតដោយបារមីនៃព្រះភគវា
ធ្វើទានឥតមានរួញរា កាលដែលនៅជាព្រះពោធិសត្វ ។
-រស្មីពណ៌ខៀវនោះណា កាលធ្លៀលនេត្រាទ្រង់ដោយចិត្តកាត់
ឱ្យទានដល់ឥន្ទព្រាហ្មណ៍ពិត កាលនៅជាក្សត្រនាមស្រីពិរាស្ត្រ ។
-រស្មីពណ៌លឿងភ្លឺថ្វា កាលដែលទ្រង់អារសាច់ផែរធ្វើមាស
បិទពុទ្ធរូបភ្លឺល្អឱភាស ព្រះឥន្ទជាងមាសទ្រង់វៃបណ្ឌិត ។
-រស្មីក្រហមនោះណា កាលដែលមាតាពស់ខាំស្លាប់ពិត
បទុមស្លឹបប្តូរជីវិត កាត់បេះដូងបិទធ្វើថ្នាំមាតា។
-រស្មីពណ៌សសុទ្ធសាធ កាលជាព្រះវេស្សន្តរក្សត្រា
ឱ្យទានដំរីសសោភា កាលព្រះប្រាថ្នារកពោធិញ្ញាណ ។
-រស្មីពណ៌ដូចដើងហង្ស កាលមាតាទ្រង់យក្សចាប់យកបាន
វិជ្ជាធរអារសាច់ខ្លួនប្រាណ ឱ្យយក្សសាមានស៊ីប្តូរជីវិត ។
-រស្មីពណ៌ផ្ទែកពណ្ណរាយ កាលជាទន្សាយឈ្មោះសសបណ្ឌិត
ឱ្យទានសាច់ឈាមជីវិត ដល់ឥន្ទព្រាហ្មណ៍ពិតថាអត់អាហារ។
-រស្មីខៀវលឿងក្រហម សហង្សបាទព្រមភ្លឺផ្ទែកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ ក្មេងចាស់កុមារចង់ចាំទុកអើយ ៕

បទសរភញ្ញ (បទបថ្យាវត្ត)

១.សូមថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេព្តា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ ។
២.ចង្អុលឲ្យដើរផ្លូវកណ្តាល មាគ៌ាត្រកាលអាចកម្ចាត់
ទុក្ខភ័យចង្រៃឲ្យខ្ចាយបាត់ អាចកាត់សង្សារទុក្ខបាន ។
៣.សាសនាព្រះអង្គនៅសព្វថ្ងៃ សត្វមាននិស្ស័យពីបូរាណ
ប្រឹងរៀនប្រឹងស្តាប់ចេះចាំបាន កាន់តាមលំអានបានក្តីសុខ ។
៤.ឥតមានសុខណាស្មើក្តីស្ងប់ បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ ក្តីសុខនិងមានព្រោះធម៌ស្ងប់។
៥.ខ្ញុំសូមបង្គំឆ្ពោះព្រះធម៌ ព្រះសង្ឃបវរទាំងគ្រប់សព្វ
រួមជាត្រៃរតន៍គួរគោរព ជាម្ចប់ត្រជាក់នៃលោកា ។
៦.ព្រះរូបព្រះធាតុនៃព្រះពុទ្ធ វិសុទ្ធតាងអង្គព្រះសាស្តា
សូមគុណត្រៃរតន៍ជួយខេមរា ឲ្យបានសុខាតរៀងទៅ ៕

រតនត្តយបូជា

ឥមេហិ ទីបធូបាទិ សក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ខ្ញុំព្រះករុណា សូមបូជាចំពោះ នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយមានទៀន និងធូបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

ពុទ្ធរតនប្បណាម

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

(សូធ្យ ៣ ចប់)

រីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្ត ដ៏ប្រសើរទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

យោ សន្និសិន្នោ វរពោធិមូលេ
មារំ សសេនំ មហតី វិជេយ្យោ
សម្ពោធិមាគច្ឆិ អនន្តញាណោ
លោកុត្តមោ តំ បណមាមិ ពុទ្ធំ ។

ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើន នូវព្រះអានាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញា រកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។

យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា
បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ។

ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកាលខាងមុខក្តី ព្រះ

សម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្រកប្បនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង ។

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

ឥតិបិ សោ ភគវា អរហំ ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេស ព្រមទាំងវាសនាគឺ កាយបយោគ និង វចីបយោគ សម្មាសម្ពុទ្ធោ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យ ណាប្រដៅព្រះអង្គឡើយ វិជ្ជាចរណសម្បន្នោ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ ដោយវិជ្ជា ៣ និង វិជ្ជា ៨ និង ចរណៈ ១៥ សុគតោ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរ

លូ យាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន លោកវិទូ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក អនុត្តរោ ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន បុរិស-ទម្មសារថិ ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន សត្ថា ទេវមនុស្សានំ ទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និង មនុស្សទាំងឡាយ ពុទ្ធោ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឱ្យត្រាស់ដឹងផង ភគវា ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ
ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។

នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹង ទីរលឹកនៃខ្ញុំព្រះ

ករុណាមិនមានឡើយ ពុទ្ធោ មេ សរណំ វរំ មានតែព្រះពុទ្ធជាម្ចាស់ជា ទីពឹងទីរឭក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណាដោយកិរិយាពោលនូវពាក្យសច្ចៈនេះៗ

ឧត្តមង្គេន វន្ទេហំ
បាទបំសុំ វរុត្តមំ
ពុទ្ធេ យោ ខលិតោ ទោសោ
ពុទ្ធោ ខមតុ តំ មមំ ៗ

ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អងធូលីព្រះបាទ នៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ដោយអវយវៈ ដ៏ឧត្តមគឺត្បូង ពុទ្ធេ យោ ខលិតោ ទោសោ ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់ ពុទ្ធោ ខមតុ តំ មមំ សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ៗ

ពុទ្ធបូជា មហាតេជោ បូជាព្រះពុទ្ធមានតេជះច្រើន !

ធម្មរតនប្បណាម

អដ្ឋង្គិការិយបថោ ជនានំ
មោក្ខប្បវេសាយ ឧជូ ច មគ្គោ
ធម្មោ អយំ សន្តិករោ បណីតោ
និយ្យានិកោ តំ បណមាមិ ធម្មំ ។

ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឱ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះ ជាធម៌ធ្វើឱ្យត្រជាក់ រម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វឱ្យចេញចាកសង្សារ-ទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះ ដោយគោរព ។

យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា
បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ។

ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ នឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុក ក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។

ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដកជាធម៌ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងហើយដោយល្អ (ធម្មោ ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១) សន្ទិដ្ឋិកោ ជាធម៌ គឺព្រះអរិយបុគ្គលទាំងពួងដឹងពិត ឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹង ដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗ ក៏ទេ គឺ ឃើញច្បាស់ដោយខ្លួនឯង អកាលិកោ ជាធម៌ឲ្យនូវផលមិនរង់ចាំ

កាល គឺជាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផល ក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ ឯហិបស្សិកោ ជាធម៌គួរដល់ ឯហិបស្សវិធី គឺជាបើព្រះអរិយបុគ្គល ដែលបាន សម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើល បាន ឱបនយិកោ ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូល មកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជា ដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

នត្ថិ មេ សរណំ អញ្ញំ   ធម្មោ មេ សរណំ វរំ
ឯតេន សច្ចវជ្ជេន   ហោតុ មេ ជយមង្គលំ ។

នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹង ទីរលឹកនៃ ខ្ញុំព្រះ ករុណាមិនមានឡើយ ធម្មោ មេ សរណំ វរំ មានតែព្រះធម៌ ជាម្ចាស់ ជាទីពឹងទីរលឹកដ៏ប្រសើររបស់ខ្ញុំព្រះករុណា ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណាដោយកិរិយាពោលនូវពាក្យសច្ចៈនេះ។

ឧត្តមង្គេន វន្ទេហំ
ធម្មញ្ច ទុវិធំ វរំ
ធម្មេ យោ ខលិតោ ទោសោ
ធម្មោ ខមតុ តំ មមំ ។

ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ ដ៏ប្រសើរមានពីរប្រការ គឺព្រះបរិយត្តិធម៌ និង ព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តម គឺត្បូង ធម្មេ យោ ខលិតោ ទោសោ ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះធម៌ជាម្ចាស់ ធម្មោ ខមតុ តំ មមំ សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

ធម្មបូជា មហាបញ្ញោ

បូជាព្រះធម៌មានបញ្ញាច្រើន !

សង្ឃរតនប្បណាម

សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ
សន្តិន្ទ្រិយោ សព្វមលប្បហីនោ
គុណេហិ នេកេហិ សមិទ្ធិបត្តោ
អនាសវោ តំ បណមាមិ សង្ឃំ ។

ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រីយ៍រម្ងាប់ហើយ មានមន្ទិល គឺរាគាទិក្កិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវៈធម៌មិនមាន គឺជាជាព្រះខីណាស្រព ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះ ដោយគោរព ។

យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា
បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ។

ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃ បានសម្រេចមគ្គនិងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះ

សង្ឃនឹងបានសម្រេចមគ្គ និងផល ក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះគ្រប់កាលទាំងពួង ។

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវក-សង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយ ដោយប្រពៃគឺប្រតិបត្តិ តាមគន្លងព្រះនព្វលោកុត្តរធម៌ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជា សាវកនៃព្រះដ៏មាន

ព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមបដិបទា ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិ ដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ពានក្សេមផុតចាកទុក្ខទាំងពួង សាមីចិ-បដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរ ដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា យទិទំ ចត្តារិ បុរិស-យុគានិ ព្រះសង្ឃឯណា បើរាប់ជាគូរនៃបុរសទាំងឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១ សកទាគាមិមគ្គ និង សកទាគាមិផលជាគូ ១ អនាគាមិមគ្គ និង អនាគាមិផលជាគូ ១ អរហត្តមគ្គ និងអរហត្តផលជាគូ ១ អដ្ឋ បុរិសបុគ្គលា បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺ ព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១

ឯស ភគវតោ សាវកសង្ឃោ ព្រះសង្ឃទាំងនោះ ជាសង្ឃសាវកនៃព្រះដ៏មានព្រះភាគ អាហុនេយ្យោ លោកគួរទទួលនូវបច្ចុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះ អ្នកមានសីល ហើយនាំមកអំពីចម្ងាយ បង្អោនចូលមកបូជា ចាហុនេយ្យោ លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែង ដើម្បីញាតិនិងមិត្ត ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា ទក្ខិណេយ្យោ លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា អញ្ជលិករណីយោ លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

ធម្មោ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ
ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។

នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណាមិនមានឡើយ សង្ឃោ មេ សរណំ វរំ មានតែព្រះសង្ឃជាម្ចាស់ជាទីពឹង ទីរលឹកដ៏ប្រសើរ របស់ខ្ញុំព្រះករុណា ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសេរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

ឧត្តមង្គេន វន្ទេហំ
សង្ឃញ្ច ទុវិធោត្តមំ
សង្ឃេ យោ ខលិតោ ទោសោ
សង្ឃោ ខមតុ តំ មមំ ។

ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរ មានពីរប្រការ គឺសម្មតិសង្ឃ និងអរិយសង្ឃដោយអវយវៈដ៏ឧត្តមគឺត្បូង សង្ឃេ យោ ខលិតោ ទោសោ ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយ

ក្នុងព្រះសង្ឃជាម្ចាស់ សង្ឃោ ខមតុ តំ មមំ សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

សង្ឃបូជា មហាជធំ បូជាព្រះមានទ្រព្យច្រើន !

រតនប្បណាមគាថា

យោ កប្បកោដីហិបិ អប្បមេយ្យំ
កាលំ ករោន្តោ អតិទុក្ករានិ
ខេទំ គតោ លោកហិតាយ នាថោ
នមោ មហាការុណិកស្ស តស្ស ។

ពុទ្ធជាទីពឹង ជាពុំនឹងសព្វសត្វា
ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ ។
រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ
បានត្រាស់ជាសព្វញ្ញូ ច្បាស់ជាគ្រូលើភពឋាន ។
ធ្វើកម្មជាកម្រ សត្វនិករត្រាប់ពុំបាន
តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ ។
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់
ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។

អសម្ពុជំ ពុទ្ធនិសេវិតំ យំ
ភវាភវំ គច្ឆតិ ជីវលោកោ
នមោ អវិជ្ជាទិកិលេសជាល-
វិទ្ធំសិនោ ធម្មវរស្ស តស្ស ។

សត្វតែងកើតស្លាប់បង់ | ចំណងកម្មជាគោល
ឱ្យវិលវល់អន្ទោល | ក្នុងភពតូចនិងភពធំ ។
ហេតុតែមិនដឹងធម៌ | បរិសុទ្ធល្អស្អាតសុខុម
គឺព្រះពុទ្ធសេពសម | ចិត្តខ្ញុំសូមនមស្ការ ។
នូវធម៌ប្រពៃពិត | វិសេសសុទ្ធនោះឯងណា
កាត់បង់នូវអវិជ្ជា | គឺបណ្ដាញកិលេសហើយ ។

គុណេហិ យោ សីលសមាធិបញ្ញា-
វិមុត្តិញាណប្បភូតីហិ យុត្តោ
ខេត្តញ្ជនានំ កុសលត្ថិកានំ
តមរិយសង្ឃំ សិរសា នមាមិ ។

ព្រះសង្ឃអង្គសាវក | មានសំវរៈសទ្ធាទ្រង់
កបដោយគុណសីលត្រង់ | និងសមាធិបញ្ញា

និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្តព្រះទសពល ជាមង្គលដល់សព្វសត្វ ។

ឥច្ចេវមច្ចន្តនមស្សនេយ្យំ
នមស្សមានោ រតនត្តយំ យំ
បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ
តស្សានុភាវេន ហតន្តរាយោ ។

ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា ។
សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ
សូមឲ្យកម្ចាត់បង់ អពមង្គលទាំងឡាយ
ឱ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអនុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ។

ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់បាននិព្វានហោង ៕

នមស្ការបូជនីយវត្ថុ

វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ
សារីរិកធាតុមហាពោធឹ ពុទ្ធរូបំ សកលំ សទា ។

ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី- រិកធាតុនៃព្រះពុទ្ធ ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំឱនចិត្តបរិសុទ្ធ លើកកម្បង់អញ្ជលី ។
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី
ដែលឋិតនៅគ្រប់ទី ស្ថាននានានោះទាំងអស់ ។
ដោយតេជះនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរម្ងស់ រម្ដោះទុក្ខភ័យអន្តរាយ ។
សូមឱ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឱ្យក្លាយមកជាមិត្ត ។

សូមទាន់ព្រះអរិ- យមេត្រីថ្ងៃវិសិដ្ឋ

សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ៕

នមស្ការពុទ្ធប្បាទ

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ

តិលោកកេតុំ តិភវេកនាថំ

យោ លោកសេដ្ឋោ សកលំ

កិលេសំ ឆេត្វាន ពោធេសិ ជនំ អនន្តំ ។

ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់បានហើយ ញ៉ាំងជនជាអនន្ត ឱ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុតអំពីច្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយ ជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។

យំ នម្មទាយ នទិយា បុលិនេ

ច តីរេ យំ សច្ចពន្ធគិរិកេ

សុមនា ចលគ្គេ យំ តត្ថ យោនកបុរេ

មុនិនោ ច បាទំ តំ បាទលញ្ឆន-
មហំ សិរសា នមាមិ ។

ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើផ្ទះខ្សាច់ទៀបឆ្នេរនៃស្ទឹង ឈ្មោះនម្មទា ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើភ្នំសច្ចពន្ធ និង លើភ្នំសុមនកូដ ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) ក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំដោយត្បូង ចំពោះទៅព្រះបាទ និង ស្នាមព្រះបាទទាំងនោះនៃព្រះសក្យមុនី ។

សុវណ្ណមាលិកេ សុវណ្ណបព្វតេ
សុមនកូដេ យោនកបុរេ
នម្មទាយ នទិយា បញ្ចបាទវរំ
ឋានំ អហំ វន្ទាមិ ទូរតោ ។

ខ្ញុំសូមនមស្ការ អំពីចម្ងាយនូវស្ថាន ដែលមានព្រះបាទដ៏ប្រសើរ ៥ កន្លែង គឺស្ថានលើភ្នំសុវណ្ណមាលិក ១ លើភ្នំសុវណ្ណបព៌ត ១ លើភ្នំសុមនកូដ ១ ក្នុងយោនកបុរី ១ ក្បែរស្ទឹងនម្មទា ១ ។

វិធីសមាទានសីល ៥

ឧកាស (អហំ/មយំ) ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចសីលានិ យាចា(មិ/ម) ។ (ម្នាក់ឯងត្រូវសូធ្យថា អហំ/មិ, ពីរនាក់ឡើងទៅ ត្រូវសូធ្យថា មយំ/ម)

ទុតិយម្បិ (អហំ/មយំ) ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចសីលានិ យាចា(មិ/ម) ។

តតិយម្បិ (អហំ/មយំ) ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចសីលានិ យាចា(មិ/ម) ។

ខ្ញុំសូមគោរព បពិត្រព្រះករុណាដ៏ចម្រើន (ខ្ញុំព្រះករុណា/ខ្ញុំព្រះករុណាទាំងឡាយ) សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ និងរក្សាផ្សេងៗគ្នា ។

បពិត្រព្រះករុណា...រក្សាផ្សេងៗគ្នា ជាគម្រប់ពីរដងផង ។

បពិត្រព្រះករុណា...រក្សាផ្សេងៗគ្នា ជាគម្រប់បីដងផង ។

ការទទួលសរណគមន៍ និង
សមាទានសិក្ខាបទ ៥

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

(សូធ្យ ៣ ចប់)

 វីកិរិយានមស្ការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹង នូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ ។

 ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ។

 ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ។

 សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ។

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវ
ព្រះពុទ្ធ ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវ
ព្រះធម៌ ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវ
ព្រះសង្ឃ ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវ
ព្រះពុទ្ធ ជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវ
ព្រះធម៌ ជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់
នូវព្រះសង្ឃ ជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

ហើយព្រះសង្ឃពោលថា តិសរណគ្គហណំ បរិបុណ្ណំ
កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍ចប់បរិបូរណ៍តែប៉ុណ្ណោះ

ត្រូវទទួលថា អាម ភន្តេ ព្រះករុណា លោកម្ចាស់ ។

ហើយលោកឱ្យផ្ដិតសីលជាបច្ចេកសមាទានថា

១. បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជា ហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។

២. អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជា ហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យដោយកាយ ឬ ដោយវាចា ។

៣. កាមេសុមិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

៤. មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

៥. សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។

រួចហើយលោកអ្នកឱ្យសីលពោលក្រើនរំឭកថា

ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។

អ្នកទាំងឡាយគប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៥ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អអស់កាលជានិច្ច ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវទទួលថា អាម ភន្តេ ព្រះករុណាលោកម្ចាស់ ។

លោកអ្នកឱ្យសីលសម្តែងសីលានិសង្សថា

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។

សត្វទាំងឡាយទៅកាន់ស្ថានសួគ៌ ក៏ព្រោះសីល, សត្វទាំងឡាយបានបរិបូរណ៍ដោយភោគៈ ក៏ព្រោះសីល, សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខពោល គឺព្រះនិព្វាន ក៏ព្រោះសីល, ព្រោះហេតុនោះ បុគ្គលជាសប្បុរសគប្បីជម្រះនូវសីលឱ្យបរិសុទ្ធ គឺថាកុំឱ្យសៅហ្មងឡើយ ។

អ្នកសមាទានទទួលថា សាធុ សាធុ សាធុ ប្រពៃហើយលោកម្ចាស់ ៕

វិធីសមាទានសីល ៨

ឱកាស (អហំ/មយំ) ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចា (មិ/ម) អនុគ្គហំ កត្វា សីលំ ទេថ(មេ/នោ) ភន្តេ ។ (ម្នាក់ឯងត្រូវសូធ្យថា អហំ/មិ/មេ, ពីរនាក់ឡើងទៅ ត្រូវ សូធ្យថា មយំ/ម/នោ)

ទុតិយម្បិ (អហំ/មយំ) ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចា (មិ/ម) អនុគ្គហំ កត្វា សីលំ ទេថ(មេ/នោ) ភន្តេ ។

តតិយម្បិ (អហំ/មយំ) ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចា(មិ/ម) អនុគ្គហំ កត្វា សីលំ ទេថ(មេ/នោ) ភន្តេ ។

ខ្ញុំសូមគោរព បពិត្រព្រះករុណាដ៏ចម្រើន (ខ្ញុំព្រះករុណា/ខ្ញុំព្រះករុណាទាំងឡាយ) សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍និងរក្សាផ្សេងៗ គ្នា បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តា ធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ (ខ្ញុំព្រះករុណា/ ខ្ញុំព្រះករុណាទាំងឡាយ) ។

បពិត្រព្រះករុណា...រក្សាផ្សេងៗគ្នា ជាគម្រប់ពីរដងផង ។

បពិត្រព្រះករុណា...រក្សាផ្សេងៗគ្នា ជាគម្រប់បីដងផង ។

ការទទួលសរណគមន៍
និង សមាទានសិក្ខាបទ ៨

លោកអ្នកឱ្យសីលត្រូវពោលតាំង ឯមោ ៣ ចប់ ហើយឱ្យព្រះត្រៃសរណគមន៍ និង អ្នកសមាទានត្រូវទទួលថា តាមលោកដូចវិធីសមាទាន **និច្ចសីល** (**សីល៥**) *ខាងដើម ។*

រួចលោកឱ្យនូវឧបោសថសីលជាបច្ចេកសមាទានថា:

១. បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

២. អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជា ហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុ ដែលគេមិនបាន ឱ្យដោយកាយ ឬ ដោយវាចា ។

៣. អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

៤. មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជា ហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

៥. សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

៦. វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជា ហេតុវៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ។

៧. នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជា ហេតុវៀរចាកកិរិយារាំ និងច្រៀង និងប្រគំ និង មើលនូវល្បែង ដែលជាសត្រូវ ដល់កុសលធម៌ និងកិរិយាទ្រទ្រង់ និងប្រដាប់តាក់តែង ស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

៨. ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺ ចេតនាជាហេតុវៀរចាកទីសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និង ទីសេនាសនៈដ៏ប្រសើរ ។

រួចហើយអ្នកសមាទានត្រូវសូធ្យកំណត់ឧបោសថកាលថា

ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ។

ខ្ញុំព្រះករុណាសូមសមាទាននូវឧបោសថសីល ដ៏ប្រកប ដោយអង្គប្រាំបី ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់បញ្ញត្ត ទុកហើយនេះ ដើម្បីនឹងរក្សា ឱ្យបរិបូណ៌ប្រពៃ អស់កាល កំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូរជាឧបនិស្ស័យ ធ្វើឱ្យ ច្បាស់នូវព្រះនិព្វាន ក្នុងអនាគតទៅឯមុខនោះហោង ។

<u>រួចហើយលោកអ្នកឱ្យសីលពោលក្រើនរំឭកថា</u>

ឥមានិ អដ្ឋ សិក្ខាបទានិ ឧបោសថសីលវសេន ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ ។

អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះ ឱ្យប្រពៃ ត្រូវរក្សាឱ្យល្អ ដោយអំណាចនៃឧបោសថសីល អស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់ ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេស ប្រហែសឡើយ ។

<u>អ្នកសមាទានត្រូវទទួលថា</u> អាម ភន្តេ ព្រះករុណាលោកម្ចាស់ ។

<u>លោកអ្នកឱ្យសីលសម្តែងសីលានិសង្សថា</u>

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។

សត្វទាំងឡាយទៅកាន់ស្ថានសួគ៌ ក៏ព្រោះសីល, សត្វទាំងឡាយបានបរិបូរណ៌ដោយភោគៈ ក៏ព្រោះសីល, សត្វ

ទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខ ពោលគឺព្រះនិព្វាន ក៏ព្រោះសីល, ព្រោះហេតុនោះ បុគ្គលជាសប្បុរសគប្បីជម្រះនូវសីលឱ្យបរិសុទ្ធ គឺថាកុំឱ្យសៅហ្មងឡើយ ។

អ្នកសមាទានទទួលថា សាធុ សាធុ សាធុ ប្រពៃហើយលោកម្ចាស់ ៕

ពុទ្ធជយមង្គល

១. ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ
គ្រីមេខលំ ឧទិតឃោរសសេន មារំ
ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទលោកចារ្យ ផ្ចាញ់ក្រុមមារចិត្តមោហន្ធ និម្មិតដៃមួយពាន់ កាន់សាស្ត្រាវុធនានា ។ ជិះគ្រីមេខលជាតិ កោញ្ចនាទខ្ទរពសុធា ព្រមដោយមារសេនា ពន្ទឹកលន់កងសព្ទស៊ាន ។ ដោយធម្មពិធី ទានបារមីជាប្រធាន ក្រុមមារចាញ់ទ្រង់ញាណ

ប្រណាម្យកាយថ្វាយវន្ទា ។ វិជយមង្គល ចូរមានដល់ អ្នករាល់គ្នា ដោយតេជះជយា ព្រះឈ្នះមារគ្រានោះហោង ។

២. មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ
ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ
ខន្តី សុទន្តវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិននាយកៈ ផ្ចាញ់អាឡវយក្ខឃោរឃៅ រឹងរូស មិនតាំងនៅ ក្នុងខន្តីគុណសត្យា ។ រហូតដល់រាត្រី ព្រះជិនស្រី ទ្រង់យុទ្ធនា ក្រៃលែង ក្រុងមារា ក្នុងបឋមសម្ពោធី ។ ដោយព្រះពិធីញាណ ទ្រង់ទូន្មាន ដោយខន្តី ញុាំងចិត្តអសុរីឱ្យបង់ព្យុះចុះវន្ទា ។ វិជយមង្គលចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ព្រះឈ្នះអាឡវយក្ខហោង ។

៣. នាឡាគិរឹ គជវរំ អតិមត្តភូតំ
ទាវគ្គិចក្កមសនីវ សុទារុណន្តំ

មេត្តម្ពុសេកាវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទ្រពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡាគិរីវរគជា ដ៏ហានក្លាចុះប្រេងព្រេច ។ សាហាវឆាវឆេះក្រៃ ដូចភ្លើងព្រៃឆេះកម្ទេច មុតដូចចក្រក្រុតពេជ្រ ខ្លាំងដូចកម្មអសនី ។ ដោយព្រះវិធីស្រព ស្រោចទឹកអប់គឺបារមី មេត្តាព្រះជិនស្រី ញុំាងដំរីឱ្យជ្រះថ្លា ។ រីជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយាព្រះឈ្នះនាឡាគិរី ។

៤. ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ
ធាវន្តិ យោជនបថង្គុលិមាលវន្តំ
ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទ្រពិនលោកត្រៃ មានព្រះទ័យធ្វើបាដិហារ្យ ផ្ចាញ់ចោរអង្គុលិមាល មានកម្រងគឺម្រាមដៃ នៃមនុស្សដែលគាត់កាត់

មកដោតចាក់ ជាមាល័យ អង់អាចអំណាចក្រៃ ដ៏មានដៃស្ទាត់ប្រហារ ។ កាន់ដាវដើរគ្រវី ដេញព្រះមុនីសាស្ដាចារ្យ ចម្ងាយផ្លូវកន្តារ កណ្ដាលព្រៃបីយោជនា ។ វិជយមង្គល ចូរមានដល់អ្នកពាល់គ្នា ដោយតេជះជយា ព្រះឈ្នះអង្គុលិមាល ។

៥. កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា
ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ
សន្តេន សោមវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ទ្រុស្តពាក្យនាងចិញ្ចា អំពើធ្វើដូចជា ស្រីមានគភ៌ចាស់ចើលពោះ ។ យកឈើធ្វើជាកូន ព័ទ្ធពោះខ្លួនពោលទ្រគោះ ព្រះពុទ្ធឈ្នះកាលនោះ ដោយសមាចារពិធី ។ រម្ងាប់ពាក្យចណ្ឌាល នាកណ្ដាលជនប្រុសស្រី ចិញ្ចាចាញ់បារមី គឺសច្ចំ ពាក្យសត្យា ។ វិជយមង្គល ចូរមានដល់អ្នកពាល់គ្នា ដោយតេជះជយា ព្រះសាស្ដាឈ្នះចិញ្ចា ។

៦. សច្ចំ វិហាយមតិសច្ចកាវាទកេតុំ
វាទាភិរោបិតមនំ អតិអន្ធភូតំ
បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ រុងរឿងស្វាងដោយបញ្ញា ផ្ចាញ់សច្ចកៈជា និគ្រន្ថក្រៅពុទ្ធវិន័យ ។ អធ្យាស្រ័យ លះបង់ពាក្យសត្យត្រង់តាមគាប់ចៃ សរសើរខ្លួនឯងក្រៃ លើកកម្ពស់ដូចដងទង់ បង្កើតមួរងងឹត ដោយពោលឥត ពាក្យទៀងត្រង់ ព្រះទ្រង់កម្ចាត់បង់ ដោយប្រទីបគឺបញ្ញា ។ វិជយមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ព្រះឈ្នះសច្ចកនិគ្រន្ថ ។

៧. នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ
បុត្តេន ថេរភុជគេន ទមាបយន្តោ
ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិនទ្រង់ញាណ ញ៉ាំងមោគ្គល្លានមានអំណាច ឱ្យប្លែងជានាគរាជ ទៅទូន្មានព្យុះកុជង្គ ។ ឈ្មោះនន្ទោបនន្ទ ចិត្តមោហន្ធ រឿងឫទ្ធិរុង ទិដ្ឋិកាចទ្រនង់ ទ្រង់ផ្ចាញ់ដោយពិធីឈាន គឺឱ្យឧបទេស ឫទ្ធិវិសេសដល់មោគ្គល្លាន ឫទ្ធិនាគអន្តរធាន ឱនចុះចាញ់ព្រះចេស្តា ។ វិជយមង្គល ចូរមានដល់អ្នករាល់ គ្នាដោយតេជះជយា ព្រះភគវាឈ្នះនាគហោង ។

៨. ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ
ព្រហ្មំ វិសុទ្ធិជុតិមិទ្ធិពកាភិធានំ
ញាណាគទេន វិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិនគោតម ផ្ចាញ់មហាព្រហ្មឈ្មោះ ពកា សម្គាល់ថាអាត្មា រុងរឿងដោយគុណវិសុទ្ធ ។ ដៃកាន់អាសិរពិស គឺ ចិត្តទ្រឹស្តិដ៏មោះមុត កាន់ខុសផ្លូវសម្ពុទ្ធ មិនលើកលាកលះបង់ប្រាណ ។ ទ្រង់ឈ្នះដោយពិធី ឱសថ វិសេសសម្រាន្ត ផ្សំត្រូវគាប់

សន្តាន គឺព្រះញាណប្រោសទេសនា ។ វិជយមង្គល ចូរមានដល់ អ្នករាល់គ្នា ដោយតេជះជយា ឈ្នះព្រហ្ម ឥតមានហ្មង ។

ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា
យោ វាចនោ ទិនទិនេ សរតេ មតន្ទី
ហិត្វានេកវិវិធានិ ចុបទ្ទវានិ
មោក្ខំ សុខំ អធិគមេយ្យ នរោ សបញ្ញោ ។

យោ នរោ ជនឯណា កបបញ្ញាប្រាសក្តីខ្ជិល ឧស្សាហ៍ សាងទាន សីល សូធ្យរំលឹកព្រះធម៌ថ្ងៃ ។ គាថាប្រាំបីបទ នេះ កំណាត់ឈ្មោះពុទ្ធជ័យ ខំសូធ្យសព្វៗថ្ងៃ កើតមង្គលជានិរន្តរ៍ ។

សោ នរោ វីជននោះ បានរំដោះរោគអាសន្ន ឧបទ្រព អនេកលន់ មានប្រការផ្សេងៗផង នឹងដល់ធម៌ក្សេមក្សាន្ត គឺ និព្វានសុខកន្ទង់ លែងទុក្ខ ទាំងបួនកង ដោយពុទ្ធជ័យមង្គល នេះ ៕

បារមី ៣០

ឥតិបិ ទានបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយទានបារមី ដូច្នេះផង ។

ឥតិបិ ទានឧបបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយទានឧបបារមីដូច្នេះផង ។

ឥតិបិ ទានបរមត្ថបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយទានបរមត្ថបារមី ដូច្នេះផង ។

ឥតិបិ សីលបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយសីលបារមី ដូច្នេះផង ។

ឥតិបិ សីលឧបបារមី សម្បន្នោ សោ ភគវា ព្រះដ៏មាន ព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយសីលឧបបារមី ដូច្នេះផង ។

ឥតិបិ សីលបរមត្ថបារមី សម្បន្នោ សោ ភគវា ព្រះដ៏មាន ព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយសីលបរមត្ថបារមី ដូច្នេះផង ។

ឥតិបិ នេក្ខម្មបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយនេក្ខម្មបារមី ដូច្នេះផង ។

ឥតិបិ នេក្ខម្មឧបបារមី សម្បន្នោ សោ ភគវា ព្រះដ៏មាន ព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយនេក្ខម្មឧបបារមី ដូច្នេះផង ។

ឥតិបិ នេក្ខម្មបរមត្ថបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយនេក្ខម្មបរមត្ថបារមី ដូច្នេះផង ។

ឥតិបិ បញ្ញាបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយបញ្ញាបារមី ដូច្នេះផង ។

ឥតិបិ បញ្ញាឧបបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយបញ្ញាឧបបារមី ដូច្នេះផង ។

ឥតិបិ បញ្ញាបរមត្ថបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយបញ្ញាបរមត្ថបារមី ដូច្នេះផង ។

ឥតិបិ វិរិយបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយវិរិយបារមី ដូច្នេះផង ។

ឥតិបិ វិរិយឧបបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ដោយវិរិយឧបបារមីដូច្នេះផង ។

ឥតិបិ វិរិយបរមត្ថបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយវិរិយបរមត្ថបារមី ដូច្នេះផង ។

ឥតិបិ ខន្តិបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយខន្តិបារមី ដូច្នេះផង ។

ឥតិបិ ខន្តិឧបបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយខន្តិឧបបារមី ដូច្នេះផង ។

ឥតិបិ ខន្តិបរមត្ថបារមី សម្បន្នោ សោ ភគវា ព្រះដ៏មាន ព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយខន្តិបរមត្ថបារមី ដូច្នេះផង ។

ឥតិបិ សច្ចបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគ អង្គនោះ ព្រះអង្គបរិបូរណ៍ ដោយសច្ចបារមី ដូច្នេះផង ។

ឥតិបិ សច្ចឧបបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះ ភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយសច្ចឧបបារមីដូច្នេះផង ។

ឥតិបិ សច្ចបរមត្ថបារមី សម្បន្នោ សោ ភគវា ព្រះដ៏មាន ព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយសច្ចបរមត្ថបារមី ដូច្នេះផង ។

ឥតិបិ អធិដ្ឋានបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះ ភាគអង្គនោះ ព្រះអង្គបរិបូរណ៍ដោយអធិដ្ឋានបារមីដូច្នេះផង ។

ឥតិបិ អធិដ្ឋានឧបចារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយអធិដ្ឋានឧបបារមី ដូច្នេះផង ។

ឥតិបិ អធិដ្ឋានបរមត្ថចារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយអធិដ្ឋានបរមត្ថបារមី ដូច្នេះផង ។

ឥតិបិ មេត្តាចារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយមេត្តាបារមី ដូច្នេះផង ។

ឥតិបិ មេត្តាឧបចារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយមេត្តាឧបបារមី ដូច្នេះផង ។

ឥតិបិ មេត្តាបរមត្ថបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយមេត្តាបរមត្ថបារមី ដូច្នេះផង ។

ឥតិបិ ឧបេក្ខាបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយឧបេក្ខាបារមី ដូច្នេះផង ។

ឥតិបិ ឧបេក្ខាឧបបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយឧបេក្ខាឧបបារមី ដូច្នេះផង ។

ឥតិបិ ឧបេក្ខាបរមត្ថបារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយឧបេក្ខាបរមត្ថបារមី ដូច្នេះផង ។

ឥតិបិ សមត្ថិសចារមី សម្បន្នោ សោ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូរណ៍ ដោយបារមីតាំង ៣០ ដូច្នេះផង ។

អនុស្សតិ ១០

១- **ពុទ្ធានុស្សតិ** ការរលឹករឿយៗចំពោះគុណព្រះពុទ្ធ ។

២- **ធម្មានុស្សតិ** ការរលឹករឿយៗចំពោះគុណព្រះធម៌ ។

៣- **សង្ឃានុស្សតិ** ការរលឹករឿយៗចំពោះគុណព្រះសង្ឃ ។

៤- **សីលានុស្សតិ** ការរលឹករឿយៗចំពោះសីលរបស់ខ្លួន ។

៥- **ចាគានុស្សតិ** ការរលឹករឿយៗ ចំពោះទានដែលខ្លួនបានបរិច្ចាគហើយ ។

៦- **ទេវានុស្សតិ** ការរលឹករឿយៗចំពោះគុណធម៌ដែលធ្វើឲ្យបុគ្គលបានកើតជាទេវតា ។

៧- ឧបមានុស្សតិ *ការរលឹករឿយៗចំពោះធម៌ ជាទីស្ងប់រម្ងាប់ គឺព្រះនិព្វាន ។*

៨- មរណានុស្សតិ *ការរលឹករឿយៗ ចំពោះសេចក្តីស្លាប់ ។*

៩- កាយគតានុស្សតិ *ការរលឹករឿយៗ ចំពោះកាយឲ្យឃើញ ជាមិនស្អាត មិនល្អ ។*

១០- អានាបានុស្សតិ *ការរលឹករឿយៗ ចំពោះ ខ្យល់ដកដង្ហើម ដែលដកចេញដកចូល ។*

⭐ មេត្តា ករុណា មុទិតា ឧបេក្ខា

⭐ នាមរូបំ អនិច្ចំ នាមរូបំ ទុក្ខំ នាមរូបំ អនត្តា ។

បត្តិទានគាថា

យំ កិញ្ចិ កុសលកម្មំ   កត្តព្វំ កិរិយំ មម
កាយេន វាចា មនសា   តិទសេ សុគតំ កតំ ។
យេ សត្តា សញ្ញិនោ អត្ថិ   យេ ច សត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ   សព្វេ ភាគី ភវន្តុ តេ ។
យេ តំ កតំ សុវិទិតំ   ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ថ ន ជានន្តិ   ទេវា គន្ត្វា និវេទយុំ ។
សព្វេ លោកម្ហិ យេ សត្តា   ជីវន្តាហារហេតុកា
មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសា ។

យំ កិញ្ចិ ប្រែភាព្យ

ទានដែលខ្ញុំបានធ្វើហើយ   ព្រះគុណអើយសូមសច្ចា
ឧទ្ទិសផលនេះណា   ជូនមាតាបិតាខ្ញុំ ។
ជីដូននិងជីតា   គ្រូអាចារ្យទាំងតូចធំ
ញាតិមិត្តគ្រប់និគម   មកជួបជុំទទួលផល ។

ដែលកូនចៅបានធ្វើ　　　　នូវអំពើជាកុសល
សូមទានឲ្យបានដល់　　　　ទោះមណ្ឌលឆ្ងាយយ៉ាងណា ។
កុសលទាំងអស់ហ្នឹង　　　　សូមទីពឹងលើទេវតា
ដែលមានចិត្តមេត្តា　　　　នាំផលាទាំងអស់នេះ ។
ទៅជូនឲ្យខ្ញុំផង　　　　ដូចបំណងកុំបីធ្វេស
កូនចៅនៅឯណេះ　　　　មិនប្រហែសបញ្ជូនទៅ ។
សូមមានចិត្តរីករាយ　　　　ដោយសប្បាយទទួលយក
កូនចៅបានលៃលក　　　　បញ្ជូនមកលោកគ្រប់ប្រាណ ។
ដើម្បីសោយកម្សាន្ត　　　　សូមឲ្យបាននៅសុខជា
កូនចៅទាំងអស់គ្នា　　　　បានបូជាជូនទៅហោង ៕

យំ កិញ្ចិ ប្រែភាព្យមួយបែបទៀត

កុសលកម្មតិចតួចឯណា ដែលចិត្តជ្រះថ្លាហើយខ្ញុំបានធ្វើ

ដោយកាយវាចាចិត្តខ្ញុំអើពើ គួរនាំទៅលើកើតឋានត្រៃត្រិង្ស។

សត្វមានសញ្ញាឯណាបានដឹង បុណ្យដែលខ្ញុំប្រឹងខំធ្វើនេះក្តី

សូម្បីពួកសត្វជាអសញ្ញី ក៏ខ្ញុំគប្បីចែកបុណ្យនេះឲ្យ ។

ថាបើពួកសត្វនោះមិនដឹងហើយ ក៏ខ្ញុំសូមឲ្យទេវតាមានឫទ្ធិ

អញ្ជើញទៅប្រាប់ទៅដាស់តឿនចិត្ត

ដោយក្តីអាណិតសត្វក្នុងលោកា ។

ឲ្យបានដឹងហើយដោយចិត្តមេត្តា

ត្រេកអរគ្រប់គ្នាក្នុងលោកទាំងមូល

សូមមានអាហាររស់នៅដោយស្រួល

ដោយបានទទួលផលបុណ្យនេះហោង ៕

តេជះខ្ញុំសាង (ភាព្យ)

តេជះខ្ញុំសាង សម្អិតសម្អាង ឱនកាយវាចា
សូមសុខសោភា រួចពីទុក្ខា ឆ្ពងដល់ត្រើយមហា
ពោលគឺនិព្វាន ។
គ្រប់ជាន់គ្រប់ជាតិ កុំឲ្យខ្ញុំឃ្លាត ពីសីលនិងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ស្ថានថ្ងៃថ្វា ។
ខ្ញុំជូនមគ្គផល ចំពោះទៅដល់ មាតាបិតា
គុណគ្រូឧប- ជ្ឈាយាចារ្យ គុណញាតកា
ប្រាំពីរសន្តាន ។
ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកស្ថាន
ខ្ញុំជូនមគ្គផល កុសលច្រើនថ្កាន សូមសុខក្សេមក្សាន្ត
ដល់ស្ថានផុតទុក្ខ ។

សូមសច្ចា កើតជាតិណាៗ សូមឲ្យខ្ញុំសុខ
សូមមានបញ្ញា ភ្លឺថ្លាមុះមុត រួចផុតពីទុក្ខ
ដល់និព្វានហោង ៕

វិសាខាឧបាសិកា

សេចក្ដីត្រិះរិះរបស់ខ្ញុំថា

តើនៅពេលណាខ្ញុំបានថ្វាយទាន

នូវប្រាសាទថ្មីតាមទ្រព្យដែលមាន

ជាវិហារទានថ្វាយចំពោះសង្ឃ ។

សេចក្ដីត្រិះរិះរបស់ខ្ញុំថា

តើនៅពេលណាខ្ញុំបានឱនអង្គ

ថ្វាយគ្រឿងពួកខ្មើយដោយចិត្តផ្ចិតផ្ចង់

ចំពោះដល់សង្ឃដែលគង់ក្នុងវត្ត ។

សេចក្តីត្រិះរិះរបស់ខ្ញុំថា

តើនៅពេលណាខ្ញុំបានថ្វាយកត្ត

ផ្សំដោយមំសៈធ្វើដោយហ្មត់ចត់

សលាកកត្តជាអាហារទាន ។

សេចក្តីត្រិះរិះរបស់ខ្ញុំថា

តើនៅពេលណាជួបព្រះទ្រង់ញាណ

ព្រមទាំងព្រះសង្ឃសទ្ធាខ្ញុំមាន

ថ្វាយចីវរទានសំពត់សាច់ល្អ ។

សេចក្តីត្រិះរិះរបស់ខ្ញុំថា

តើនៅពេលណាជួបសង្ឃបវរ

ថ្វាយភេសជ្ជៈទឹកឃ្មុំប្រេងស្ករ

ទឹកដោះគោល្អនិងទឹកអំពៅ ។

មកដល់ឥឡូវខ្ញុំបានសម្រេច

គ្រប់មុខស្រេចបាច់ឥតមានសល់នៅ

ខ្ញុំបានថ្វាយទានកប់ទុកយ៉ាងជ្រៅ

ក្នុងដំណើរទៅកាន់ព្រះនិព្វាន ។l

តាំងសេចក្ដីប្រាថ្នា

សូមឲ្យអ្នកទាំងឡាយ សុខសប្បាយទាំងគ្នា

កុំឲ្យមានរោគា ព្រមទាំងញាតិមិត្តសន្ដាន ។

ចូរខំប្រឹងប្រព្រឹត្ត សាងសុចរិតធម៌ឲ្យបាន

សព្វថ្ងៃសាសនាមាន ខំធ្វើទានសីលភាវនា ។

កើតមកក្នុងលោកីយ៍ ជនប្រុសស្រីមានវាសនា

ខំរៀនសូត្រធម៌អាថ៌ ទាន់សាសនាព្រះទ្រង់ញាណ ។

ត្បិតយើងមិនស្គាល់ផ្លូវ និងដើរទៅព្រះនិព្វាន

ជាទីសុខក្សេមក្សាន្ត លះបង់បានចាកមន្ទិល ៗ៕

ទានចិញ្ចឹមបុត្រ

១- ទានចិញ្ចឹមបុត្របរិសុទ្ធក្នុងផ្ទៃ

រហូតដល់ថ្ងៃបុត្រថ្ងៃចាកគភ៌

ទានចិញ្ចឹមស្មោះទឹកដោះបបរ

កូនរស់បានល្អព្រោះធម៌សប្បុរស ។

២- ទានថ្វាយដល់សង្ឃផ្នួងឧទ្ទិសទាន

ប្រេតរួចពីឃ្លានព្រោះទានរំដោះ

ទានជាទេវធម៌លម្អសប្បុរស

ទានមានចិត្តស្មោះសង្គ្រោះជីវិត ។

៣- ទានគឺជាទ្រព្យជាប់តាមសន្តាន

ទានគឺជាស្ពានឆ្លងភពផងផឹត

ទានកាច់បំបាក់មោហៈក្នុងចិត្ត

បានត្រាស់ដឹងពិតត្បិតទានបារមី ។

៤- ហៃកូនប្រុសស្រីគប្បីចាំទុក

គុណម្តាយឱពុកទានាធិបតី

កូនដឹងមង្គលសាមសិបប្រាំបី

ជៀសកម្មអប្រិយ៍ផុតភ័យអបាយ ៕

អន្លង់ទាំងបួន

បពិត្រព្រះគុណព្រះករុណា គង់លើអាសនាស័ក្កសមរម្យ

ដឹកនាំទេសនាប្រោសយើងខ្ញុំ ដើម្បីអប់រំកាយវាចា ។

យើងខ្ញុំគ្រប់គ្នាត្រូវលិចលង់ ចុះក្នុងអន្លង់បួនប្រការ

អន្លង់ទីមួយគឺកាមា ដែលពេញសត្វាក្នុងកាមគុណ ។

អន្ទង់ទីពីរ ភវោឃៈ ទាញសត្វទម្ងាក់ក្នុងទុក្ខធ្ងន់

វិលស្លាប់វិលកើតជានិរន្តរ៍ ឥតមានស្រាកស្រាន្តក្នុងភពបី ។

អន្ទង់ទីបី ទិដ្ឋោឃៈ ទាញសត្វទម្ងាក់ក្នុងអវិថី

ព្រោះទិដ្ឋិយល់មិនប្រពៃ បុណ្យក្តីបាបក្តីឥតអំពើ ។

អន្ទង់ទីបួន គឺអវិជ្ជា បាំងសត្វនានាឲ្យស្មាក់ស្មើរ

នាំសត្វវង្វេងមិនឲ្យធ្វើ អំពើបុណ្យទានសីលភាវនា ។

ហេតុនេះព្រះគុណព្រះករុណា គង់លើអាសនាព្រះធម្មា

ដឹកនាំយើងខ្ញុំទាំងអស់គ្នា ឡើងជិះនាវាព្រះត្រៃលក្ខណ៍ ។

កម្ចាត់កិលេសនិងតណ្ហា ព្រមទាំងអវិជ្ជាដោយអរិយ-

មគ្គកាច់បំបាក់សង្សារចក្រ ចូលកាន់អមតៈព្រះនិព្វានហោង។

ធម៌ផ្សាយមេត្តា

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ

អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ

អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ ។

ពួកសត្វទាំងអស់ក្នុងទិសបូព៌ ទិសអាគ្នេយ៍ ទិសទក្សិណ ទិសនិរតី ទិសបស្ចិម ទិសពាយព្យ ទិសឧត្តរ ទិសឦសាន ទិសខាងលើ ទិសខាងក្រោម សូមឲ្យជាសត្វមិនមានពៀរនឹងគ្នា សូមឲ្យមានតែសេចក្តីសុខជានិច្ច ពួកសត្វទាំងអស់ សូមកុំមានពៀរនឹងគ្នា សូមឲ្យបានតែសេចក្តីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្តីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សានូវខ្លួនឲ្យជាសុខរៀងទៅ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា

សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ ធាណិនោ ។

សត្វទាំងឡាយទាំងពួង ដែលដល់នូវសេចក្ដីទុក្ខ សូមឲ្យជាសត្វបាត់សេចក្ដីទុក្ខទៅ ដែលដល់នូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ ដែលដល់នូវសេចក្ដីសោក សូមឲ្យជាសត្វបាត់សេចក្ដីសោកទៅហោង ៕

អនុមោទនារក្ខាយាចនគាថា

អាកាសដ្ឋា ច ភុម្មដ្ឋា   ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ   ចិរំ រក្ខន្តុ សាសនំ ។

វីទេវតានិងនាគ ស្ថិតនៅនាភូមិផែនដី នៅលើអាកាសក្តីមានសិរីដ៏ឧត្តម សូមអនុមោទនានូវបុណ្យជារបស់ខ្ញុំ ហើយសូមជួយថែទាំងនូវសាសនាអស់កាលវែង ។

អាកាសដ្ឋា ច ភុម្មដ្ឋា   ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ   ចិរំ រក្ខន្តុ រាជានោ ។

វីទេវតានិងនាគស្ថិតនៅនាភូមិផែនដី   នៅលើអាកាសក្តី មានសិរីដ៏ឧត្តម សូមអនុមោទនានូវបុណ្យជារបស់ខ្ញុំ ហើយសូមជួយថែទាំនូវរាជា អស់កាលវែង ។

អាកាសដ្ឋា ច ភុម្មដ្ឋា   ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ   ចិរំ រក្ខន្តុ ញាតិយោ ។

វីទេវតានិងនាគ ស្ថិតនៅនាភូមិផែនដី នៅលើអាកាសក្តី មានសិរីដ៏ឧត្តម សូមអនុមោទនានូវបុណ្យជារបស់ខ្ញុំ ហើយសូមជួយថែទាំផនូវពួកញាតិអស់កាលវែង ។

អាកាសដ្ឋា ច ភុម្មដ្ឋា   ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ   ចិរំ រក្ខន្តុ ចាណិនោ ។

វីទេវតានិងនាគស្ថិតនៅនាភូមិផែនដី   នៅលើអាកាសក្តី មានសិរីដ៏ឧត្តម សូមអនុមោទនានូវបុណ្យជារបស់ ខ្ញុំហើយសូមជួយថែទាំនូវពួកសត្វអស់កាលវែង ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា ។

វីទេវតានិងនាគ ស្ថិតនៅនាភូមិផែនដី នៅលើអាកាសក្តី មានសិរីដ៏ឧត្តម សូមអនុមោទនានូវបុណ្យជារបស់ខ្ញុំ ហើយសូមជួយថែទាំនូវយើងខ្ញុំអស់កាលវែង ។

ថ្វាយបង្គំរតនត្រៃ

វត្ថុ គឺបុគ្គល គប្បីដល់ថ្វាយបូជា
ក្រៃលែងវត្ថុណា យ៉ាងប្រសើរជាងក្រៃពេក
ខ្ញុំបានតាក់តែងកាយ បង្គំថ្វាយចិត្តត្រង់ត្រេក
រតនៈបីជាឯក ក្នុងទីនេះសូមកុសល
ផលបុណ្យជួយកម្ចាត់ ឧបទ្រវៈកុំជិតដល់

ចង្រៃសូមកុំយល់ ចូរកុំឲ្យបង្កើតមាន
ដល់ខ្លួនយើងខ្ញុំណា តាំងសច្ចាជាប្រធាន

ចំណែកផលបុណ្យមាន សូមសម្រេចនិព្វានហោង ៕

សិទ្ធិយាចនគាថា

សិទ្ធមត្ថុ សិទ្ធមត្ថុ សិទ្ធមត្ថុ ឥទំ ផលំ
ឯតស្មឹ រតនត្តយស្មឹ សម្បសាទនចេតសោ ។

សូមផលនៃចិត្តដែលជ្រះថ្លា ក្នុងព្រះរតនត្រ័យនោះ ផលនេះ ចូរជាផលសម្រេច ចូរជាផលសម្រេច ចូរជាផលសម្រេច ។

គាសិតធម៌

ចិត្តំ ទន្តំ សុខាវហំ ចិត្តដែលគេទូន្មានបានល្អហើយ តែងនាំមកនូវសេចក្តីសុខ ។

នត្ថិ ខន្ធសមា ទុក្ខា សេចក្តីទុក្ខស្មើដោយខន្ធមិនមានឡើយ ។

សុខោ បញ្ញស្ស ឧច្ចយោ *ការសន្សំបុណ្យនាំមកនូវសេចក្ដីសុខ ។*

សុខំ យាវ ជរា សីលំ *សីលនាំសេចក្ដីសុខមកឲ្យរហូតដល់ចាស់ជរា ។*

ធនតោ បុញ្ញំ បវឌ្ឍតិ *បុណ្យរមែងចម្រើនដល់អ្នកឲ្យទាន ។*

សុស្សូសំ លភតេ បញ្ញំ *ការស្ដាប់ដោយល្អរមែងបាននូវបញ្ញា ។*

អធិដ្ឋានចិត្ត

សូមព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យពុទ្ធសាសនាផ្សាយទូទៅ ពេញសកលលោក សូមឲ្យលោកទាំងមូលបានប្រកបដោយសន្តិភាព ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា **នត្ថិ សន្តិបរំ សុខំ** *ពុំមានសេចក្ដីដទៃក្រៅអំពីសេចក្ដីស្ងប់ឡើយ ។*

សព្វទានំ ធម្មទានំ ជិនាតិ

ធម្មទានឈ្នះអស់ទានទាំងពួង